**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**

លេខ: ០៣៧/២១ .........អររ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១

ព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តបាត់ដំបង»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម អ៊ុយ រី ប្រធានក្រុមប្រឹក្សាខេត្តបាត់ដំបង**
- **ឯកឧត្តម សឿម ប៊ុនរិទ្ធិ អភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបង**
- **លោក យស់ យឿន ចៅសង្កាត់រតនៈ ក្រុងបាត់ដំបង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍មូលដ្ឋានឃុំ-សង្កាត់។

### I. សេចក្តីផ្តើម

ខេត្តបាត់ដំបង គឺជាខេត្តមួយដែលពឹងផ្អែកលើវិស័យកសិកម្មជាចម្បង ដោយមានប្រភពទឹក និងប្រព័ន្ធបង្ហូរទឹកជាច្រើនកន្លែង ដែលជាចំណុចខ្លាំងសម្រាប់វិស័យកសិកម្មរួមមាន៖ ស្ទឹងធំៗចំនួន៣ ដែលហូរកាត់ គឺស្ទឹងសង្កែ ស្ទឹងមោង និងស្ទឹងមង្គលបុរី និងមានវិស័យពាណិជ្ជកម្ម-ការវិនិយោគ វិស័យទេសចរណ៍-សេវាកម្ម ដែលជាវិស័យសំខាន់ៗក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចនៅក្នុងខេត្តផងដែរ។

### II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

❖ **ក្រុមប្រឹក្សាខេត្ត**

- បានរៀបចំកិច្ចប្រជុំសាមញ្ញចំនួន ១៩លើក និងកិច្ចប្រជុំវិសាមញ្ញ ០៥លើក។

- មានគណៈកម្មាធិការសំខាន់ៗចំនួន ៣រួមមាន៖
    - គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស៖ មានតួនាទីត្រួតពិនិត្យទៅលើតម្រូវការជាអាទិភាពសំខាន់ៗ ដែលមានវិសាលភាពគ្របដណ្តប់រដ្ឋបាលខេត្តទាំងមូល។
    - គណៈកម្មាធិការស្ត្រី និងកុមារ៖ ជាគណៈកម្មាធិការដែលមានភារកិច្ចផ្សាភ្ជាប់ជានិច្ចជាមួយស្ត្រី ចាស់ជរា និងកុមារ ក្នុងការអភិវឌ្ឍជីវភាពរបស់នៅប្រជាពលរដ្ឋ។
    - គណៈកម្មាធិការលទ្ធកម្ម៖ ត្រួតពិនិត្យទៅលើគម្រោងអភិវឌ្ឍនានា និងធានាគុណភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ទំនិញផ្សេងៗ។
- បានចេញដីកា និងសេចក្តីសម្រេច ចំនួន ៦គឺ៖
    - ដីកាបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខេត្ត
    - សេចក្តីសម្រេច ស្តីពីការបែងចែកជូនដល់ក្រុមប្រឹក្សាខេត្តជួបប្រាស្រ័យទាក់ទង និងសហការជាមួយក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ និងមន្ទីរ អង្គភាព
    - សេចក្តីសម្រេច ស្តីពីការបែងចែកភារកិច្ចជូនក្រុមប្រឹក្សាខេត្ត ឱ្យចូលរួមក្នុងការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ខេត្តបាត់ដំបង នៅតាមបណ្តាក្រុង ស្រុកទាំង១៤
    - សេចក្តីសម្រេច ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្ត
    - សេចក្តីសម្រេច ស្តីពីការទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាខេត្ត
    - សេចក្តីសម្រេច ស្តីពីការទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត។
- ក្រុមប្រឹក្សាបានទទួលសំណើ សំណូមពរ ចំនួន ១៨៥ ក្នុងនោះបានដោះស្រាយរួចទាំង ១៨៥។ ចំណែកឆ្នាំ២០២០ មានសំណើ សំណូមពរចំនួន ១៩៣ ក្នុងនោះបានដោះស្រាយរួច ចំនួន ១០៥ នៅសល់ចំនួន ៨៨ និងបានរៀបចំបញ្ជូនទៅតាមបណ្តាមន្ទីរ-អង្គភាពជំនាញដើម្បីដោះស្រាយ។
- បានអនុម័ត និងធ្វើការបោះពុម្ពផ្សព្វផ្សាយនូវ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ស្របតាមគោលការណ៍ណែនាំផ្នែកគោលនយោបាយ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣។
- ក្រុមប្រឹក្សាខេត្ត បានចូលរួមជាមួយគណៈអភិបាលខេត្ត ក្នុងការងារប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០នេះ មានដូចជា៖
    - ការចុះអប់រំផ្សព្វផ្សាយអំពីវិធានការការពារ និងបង្ការការឆ្លងជំងឺកូវីដ-១៩
    - ចុះសួរសុខទុក្ខអ្នកជំងឺកូវីដ-១៩ និងអ្នកដែលធ្វើចត្តាឡីស័កនៅតាមមូលដ្ឋាន
    - ចុះត្រួតពិនិត្យមើលការរៀបចំទីតាំងពិនិត្យសុខភាព នៅតាមស្រុកជាប់ព្រំដែននៃប្រទេសថៃ

- ចែកអំណោយ និងសំភារៈការពារជំងឺកូវីដ-១៩ ដល់បងប្អូនពលករដែលទើបត្រឡប់មកពីក្រៅប្រទេស
- ចូលរួមជាមួយរដ្ឋបាលខេត្ត ក្នុងការបរិច្ចាគថវិកាជូនរាជរដ្ឋាភិបាលដើម្បីទិញវ៉ាក់សាំងកូវីដ
- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយនានា ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ តាមគ្រប់រូបភាពទាំងអស់។

- ចូលរួមគាំទ្រគណៈអភិបាលខេត្ត ក្នុងការអនុវត្តមុខងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ
- បានលើកកម្ពស់ភារកិច្ច ធ្វើគណនេយ្យភាពជាមួយប្រជាពលរដ្ឋតាមរយៈ៖
  - កិច្ចប្រជុំក្រុមប្រឹក្សា ពិនិត្យមើលការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីពង្រឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ពិសេសការឆ្លើយតប តម្រូវការសេវាទីក្រុង ទីប្រជុំជន និងសេវាជនបទ។
  - ពិនិត្យមើលការឆ្លើយតបគ្រោះមហន្តរាយធម្មជាតិ និងរោគរាតត្បាត ពិសេសជំងឺកូវីដ-១៩។
  - អនុវត្តគោលនយោបាយគណនេយ្យភាពសង្គម តាមរយៈភារកិច្ចការិយាល័យប្រជាពលរដ្ឋដែលជាយន្តការគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ រួមចំណែកប្រាស្រ័យទាក់ទង ដោះស្រាយ សម្របសម្រួលទំនាស់បាន ១៩៩លើក និងជំរុញការលើកយោបល់ជាសាធារណៈ។

❖ **សង្កាត់រតនៈ ក្រុងបាត់ដំបង**

- សេដ្ឋកិច្ចរបស់សង្កាត់រតនៈ គឺពឹងផ្អែកលើ វិស័យពាណិជ្ជកម្ម វិនិយោគ និងវិស័យទេសចរណ៍ សេវាកម្ម ជាវិស័យសំខាន់ៗ ជាពិសេសសង្កាត់រតនៈ មានសក្តានុពលលើវិស័យអភិវឌ្ឍន៍ដីឡូតិ៍ និងបុរី ដែលទាក់ទាញអ្នកវិនិយោគ ជាច្រើនបានមកបណ្តាក់ទុនជាការរួមចំណែកបង្កើនមុខរបររបស់ប្រជាជនក្នុងមូលដ្ឋាន។
- ផ្នែកអប់រំ៖ មានវិទ្យាស្ថានគរុកោសល្យបាត់ដំបង ចំនួន១, សកលវិទ្យាល័យឯកជន ចំនួន២ និងសាលាបឋមសិក្សារដ្ឋ ចំនួន ៣។
- ផ្នែកកសិកម្ម ៖ កសិដ្ឋានចិញ្ចឹមក្រពើ ៤ កន្លែង, កសិករ ធ្វើស្រែ ១៣០ ហិកតា , ចំការ ២ ហិកតា
- ផ្នែកទេសចរណ៍ និង សេវាកម្ម៖ សួនច្បារសាធារណៈ មានបំពាក់ឧបករណ៍សម្រាប់ហាត់ប្រាណ, សណ្ឋាគារ ចំនួន ១៥ ទីតាំង, មាន ៧៤២ បន្ទប់, ផ្ទះសំណាក់ ចំនួន ១៥ ទីតាំង, មាន ៣០០ បន្ទប់, ផ្ទះជួល ចំនួន ៩០ ទីតាំង ,មាន ៩០៦ បន្ទប់ និង ភោជនីយដ្ឋាន ៨ ទីតាំង។

- ការងារសន្តិសុខសណ្តាប់ធ្នាប់ និងការងារភូមិឃុំមានសុវត្ថិភាព៖ ការអនុវត្តគោលនយោបាយភូមិឃុំ មានសុវត្ថិភាព រដ្ឋាភិបាលសង្កាត់ បានផ្សព្វផ្សាយអោយប្រជាពលរដ្ឋដើម្បីការពារសុវត្ថិភាពភូមិដ្ឋានរបស់យើងគ្រប់ៗគ្នា និងបាន៖
  - ដោះស្រាយ និងសម្របសម្រួលទំនាស់នានា បានចំនួន ១៥ ករណី
  - គ្រោះទឹកជំនន់៖ កើតមាន០១លើក បណ្តាលឱ្យលិចផ្ទះប្រជាពលរដ្ឋចំនួន ៧៤៦ ខ្នងផ្ទះ ។
  - ការទប់ស្កាត់សំណង់ខុសច្បាប់
  - ការពង្រឹងប៉ុស្តិ៍រដ្ឋបាលដឹកនាំប្រជាការពារ រៀបចំសណ្តាប់ធ្នាប់តាមសួនសាធារណៈ មាត់ស្ទឹងសង្កែ និង ការងារបង្ការទប់ស្កាត់ ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន
  - បានរៀបចំប្រជុំ ពិភាក្សាការងារភូមិ ឃុំ មានសុវត្ថិភាព ជាមួយអាជីវករក្នុងសង្កាត់ដើម្បីស្វែងរកមូលនិធិគាំទ្រ ប្រជាការពារសង្កាត់។

## III. ទិសដៅការងារបន្ត

❖ **ក្រុមប្រឹក្សាខេត្ត**

- បន្តជួយជ្រោមជ្រែងគណៈអភិបាលខេត្ត ក្នុងការការជំរុញកំណើនសេដ្ឋកិច្ចខេត្ត
- ផ្តល់យោបល់ និងកំណត់ទិសដៅជូនរដ្ឋបាលខេត្ត ក្នុងការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីជូនប្រជាជនប្រើប្រាស់ និងបម្រើការធ្វើអាជីវកម្ម និងការវិនិយោគ
- បន្តតាមដាន ត្រួតពិនិត្យមើលការកែលំអរ និងអភិវឌ្ឍនូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា សម្រាប់ចូលរួមចលនាប្រឡងប្រណាំងទីក្រុងស្អាត និងការទាក់ទាញភ្ញៀវទេសចរទាំងក្នុងស្រុក និងបរទេសឱ្យចូលមកកំសាន្តនៅក្នុងខេត្ត
- ជម្រុញការចុះបញ្ជីដីធ្លីទាំងលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ ដើម្បីធានាបាននូវការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឲ្យមានប្រសិទ្ធភាព និងចូលរួមកាត់បន្ថយបញ្ហាជំលោះដីធ្លី
- ជម្រុញនូវការផ្តល់សេវារដ្ឋបាល និងសេវាសារណៈជូនប្រជាពលឲ្យបានកាន់តែល្អប្រសើរ តាមរយៈច្រកចេញចូលតែមួយនៅគ្រប់លំដាប់ថ្នាក់ទាំងអស់។
- បន្តពិនិត្យមើលលើការអនុវត្តអោយបានល្អនូវគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព
- បន្តដោះស្រាយសំណូមពរទាំងឡាយរបស់ប្រជាពលរដ្ឋ ដែលបានមកតាមរយៈការធ្វើវេទិការបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់។

❖ **សង្កាត់រតនៈ ក្រុងបាត់ដំបង៖**

- បន្តការយកចិត្តទុកដាក់បម្រើសេវារដ្ឋបាល ជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស
- បន្តខិតខំពង្រឹងកំលាំងនគរបាលប៉ុស្តិ៍ និងប្រជាការពារ ដើម្បីអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព អោយបានល្អ

- ផ្សព្វផ្សាយ និង ផ្តល់ឱកាស អោយប្រជាពលរដ្ឋ យល់ដឹង អំពីច្បាប់ និង លិខិតបទដ្ឋាននានា គោលការណែនាំ បញ្ជ្រាបចំណេះដឹង ក្នុងការបង្កើតមុខរបរខ្នាតតូច ជូនដល់ប្រជាពលរដ្ឋ
- លើកកម្ពស់ការយល់ដឹងពី ផែនការគណនេយ្យភាពសង្គម
- រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល និងអនុវត្តគម្រោងមូលនិធិសង្កាត់ឱ្យបានទាន់ពេលវេលា
- បន្តផ្សព្វផ្សាយពីវិធានការការពារ ទប់ស្កាត់ជំងឺឆ្លងនានា ជាពិសេសជម្ងឺកូវីដ-១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល
- ផ្សព្វផ្សាយ ណែនាំដល់ប្រជាពលរដ្ឋអោយចេះវេចខ្ចប់ទុកដាក់សំរាម និងកាកសំណល់ឱ្យបានត្រឹមត្រូវ
- ខិតខំគៀងគរដៃគូ អ្នកវិនិយោគ សប្បុរសជន ដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងសង្កាត់។

## IV. សម្គាល់

ស្របជាមួយនឹងវឌ្ឍនភាពគួរឱ្យកត់សម្គាល់នោះ រដ្ឋបាលខេត្តក៏ជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តដោះស្រាយរួមមាន៖

- ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់មានធនធានគ្រប់គ្រាន់ និងសមត្ថភាពនៅមានកម្រិត
- ការពង្រឹងប្រសិទ្ធភាព និងសមត្ថភាពក្នុងការអនុវត្តមុខងារកាតព្វកិច្ចមិនទាន់បានឆ្លើយតបសមស្របតាមស្ថានភាពនៃការវិវត្តន៍របស់ជីវភាពសង្គម ដូចជាផ្តល់សេវាសាធារណៈសម្រាប់សេវាទីក្រុង រួមមាន អនាម័យ បរិស្ថាន សណ្តាប់ធ្នាប់សាធារណៈ និងសេវាជនបទ ក្នុងនោះមាន កសិកម្ម គមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ និងធនធានធម្មជាតិ។

ថ្ងៃចន្ទ ១២កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១